# II - រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

## អនុក្រឹត្យលេខ ២៦ អនក្រ.បក

## ស្តីពីការបង្កើតនិងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ។បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០

### សំរេច

**មាត្រា ១ .-**

អនុញ្ញាតអោយបង្កើតភ្នាក់ងារសុខភាពសត្វភូមិ ក្នុងគោលបំណងបង្កើតមុខរបរសំរាប់ប្រជាពលរដ្ឋ និងបង្កើនផលិតភាព និង គុណភាពសត្វ អោយសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីឯកជនភាវូបនីយកម្ម ក្នុងវិស័យផលិតកម្ម និងបសុព្យាបាល សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ ។

**មាត្រា ២ .-**

ភ្នាក់ងារសុខភាពសត្វភូមិនេះ មិនត្រូវជាភ្នាក់ងាររដ្ឋទេ តែជាភ្នាក់ងារដែលត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឬ សិស្ស-និស្សិតដែលបានទទួលការបណ្តុះបណ្តាល មកទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣ .-**

នីតិវិធីនៃការជ្រើសរើស ការបណ្តុះបណ្តាល ការទ្រទ្រង់សកម្មភាព ការគ្រប់គ្រងអោយមាននិរន្តរភាព តួនាទី និងភារកិច្ចរបស់ភ្នាក់ងារសុខភាពសត្វភូមិ និងគោលការណ៍ពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ២៧ អនក្រ.បក**

**ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តព្រៃវែង ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ**

**រាជរដ្ឋាភិបាល**

បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា